# <u>ពិធីការវត្តមានអវត្តមានរបស់សិស្ស៖ ឯកសារយោងរហ័ស</u>

ក្រោមច្បាប់រដ្ឋ ផិនស៊ិលវេនញ៉ា សិស្សានុសិស្សទាំងអស់ដែលមានអាយុចន្លោះពីប្រាំមួយ (៦) ដល់ ដប់ប្រាំបី (១៨) ឆ្នាំ ត្រូវតែចូលរៀនជារៀងរាល់ថ្ងៃ។ នៅពេលដែលសិស្សបានចុះឈ្មោះចូលរៀនហើយ នេះរាប់បញ្ចូលទាំងសិស្សដែលរៀនថ្នាក់មត្តេយ្យ ពួកគេត្រូវស្ថិតនៅក្រោមច្បាប់នេះរហូតដល់ពេលមានអាយុ ១៨ ឆ្នាំ។

## <u>និយមន័យ</u>

- អវត្តមានដែលគ្មានការលើកលែង ៣ ដង ឡើងទៅ = គេចសាលា (Truant)
- អវត្តមានដែលគ្មានការលើកលែង ៦ ដង ឡើងទៅ = ទម្លាប់គេចសាលា (Habitually Truant)
- អវត្តមានដែលគ្មានការលើកលែង ១០ ដង ឡើងទៅ = គេចសាលាច្រើនដង (Chronically truant)

## <u>កន្លះថ្ងៃ</u>

- <u>សាលាថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ៨៖</u> សិស្សដែលមករៀន ពីរ (២) ម៉ោង ក្រោយពេលចាប់ផ្តើមថ្ងៃរៀន ឬ ចាកចេញ ពីរ (២) ម៉ោង មុនពេលចប់ថ្ងៃរៀន នឹងត្រូវបានកត់សម្គាល់ថាអវត្តមានកន្លះថ្ងៃ។*
- <u>សាលាមធ្យមសិក្សាពិត *(សម្រាប់តែថ្នាក់ទី ៦ ដល់ទី ៨ ប៉ុណ្ណោះ)* និងវិទ្យាល័យ៖</u> សិស្សមិនត្រូវបានកត់សម្គាល់ថាអវត្តមានកន្លះថ្ងៃទេ។ សិស្សត្រូវបានកត់សម្គាល់ដោយយោងទៅតាម ថ្នាក់/រយៈពេលបង្រៀន។

**ប្រសិនបើក្មេងមានសំបុត្រពីអ្នកផ្តល់សេវាថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណ (វេជ្ជបណ្ឌិត ទន្តពេទ្យ ចិត្តបណ្ឌិត អ្នកចិត្តសាស្ត្រខាងវិកលចរិត ។ល។) ពួកគេនឹងត្រូវបានកត់សម្គាល់ថាលើកលែងឱ្យកន្លះថ្ងៃ (ព្រឹក ឬ ល្ងាច)។ សំបុត្រនោះត្រូវតែផ្តល់ឱ្យសាលា នៅពេលត្រឡប់មកពីជួបអ្នកផ្តល់សេវាថែទាំសុខភាពវិញ ក្នុងរយៈពេល ២៤ ម៉ោង នៃជំនួប។ ប្រសិនបើសិស្សគ្មានសំបុត្រទេ កន្លះថ្ងៃនឹងនៅតែគ្មានការលើកលែងឱ្យ។*

## <u>មករៀន យឺតពេល/មិនទាន់ម៉ោង</u> *(ថ្ងៃពន្យារម៉ោងចូលរៀន**មិន**រាប់ថាអវត្តមានទេ)*

- <u>សាលាថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ៨៖</u> សិស្សដែលមករៀនក្រោយម៉ោងចាប់ផ្តើមថ្ងៃរៀន ប៉ុន្តែតិចជាង ពីរ (២) ម៉ោង ក្រោយម៉ោងចាប់ផ្តើមរៀន នឹងចាត់ទុកថាមកយឺត។
- <u>សាលាមធ្យមសិក្សាពិត និងវិទ្យាល័យ៖</u> នៅពេលដែលសិស្សមកយឺត មិនស្កេនចូល ហើយទៅកាន់ថ្នាក់រៀនភ្លាម គ្រូនឹងកត់សម្គាល់ថាសិស្សមកយឺតសម្រាប់ ថ្នាក់/រយៈពេលបង្រៀន។

*ប្រសិនបើសិស្សមានសំបុត្រសុំការលើកលែងពីអ្នកផ្តល់សេវាថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណ នោះនឹងរាប់ថាជាការមករៀនយឺតពេលដែលមានការលើកលែង។*

**<u>ថ្ងៃដែលឱ្យសិស្សចេញពីរៀនមុនម៉ោង</u>** *(ថ្ងៃដែលឱ្យសិស្សចេញពីរៀនមុនម៉ោង**មិន**រាប់ថាអវត្តមានទេ)*

- សិស្សដែលចាកចេញពីសាលានៅពេលណាមួយក្នុងអំឡុងថ្ងៃរៀន ក្រៅព្រំដែនដែលបានកំណត់ក្នុងនីតិវិធី អវត្តមាន/ការឃើតយ៉ាវ កន្លះថ្ងៃ នឹងត្រូវបានកត់សម្គាល់ថា ចេញមុនម៉ោងដោយគ្មានការលើកលែង។*

**ប្រសិនបើសិស្សមានសំបុត្រសុំការលើកលែងពីអ្នកផ្តល់សេវាថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណ ពួកគេនឹងត្រូវបានកត់សម្គាល់ថាជាការចេញមុនម៉ោងដែលមានការលើកលែង។ សំបុត្រនោះត្រូវតែផ្តល់ឱ្យក្នុងរយៈពេល ២៤ ម៉ោង ក្រោយពេលសិស្សចាកចេញពីសាលា ដើម្បីឱ្យមានការលើកលែង។*

**<u>ការជូនដំណឹងរបស់មាតាបិតាអំពីអវត្តមាន (ការជូនដំណឹងតាមការសរសេរជាលាយលក្ខណ៍អក្សរ)</u>**

- ច្បាប់វត្តមានអវត្តមានរបស់ក្រសួងអប់រំតម្រូវឱ្យផ្តល់សំបុត្រសុំការលើកលែងតាមការសរសេរពន្យល់អំពីអវត្តមាន។
  - ទាក់ទងសាលារបស់ក្មេង ដើម្បីបញ្ជាក់ពីវិធីដែលអាចផ្តល់សំបុត្រសុំការលើកលែង។
  - សំបុត្រសុំការលើកលែងត្រូវតែផ្តល់ឱ្យសាលាក្នុងរយៈពេល ***បី (៣) ថ្ងៃ*** នៅពេលសិស្សត្រឡប់មកសាលាវិញ។ ប្រសិនបើមិនផ្តល់សំបុត្រនេះឱ្យសាលាក្នុងរយៈពេលដែលត្រូវការទេ ថ្ងៃនោះប្រហែលជាមិនត្រូវបានលើកលែងឱ្យទេ។
  - សំបុត្រសុំការលើកលែងត្រូវតែរួមបញ្ចូល ឈ្មោះសិស្ស ថ្ងៃខែនៃអវត្តមាន និងលេខទូរស័ព្ទដែលមានសុពលភាព ឬវិធីទាក់ទងផ្សេងទៀតសម្រាប់គោលបំណងនៃការបញ្ជាក់។
- អវត្តមានទាំងអស់ដែលបណ្តាលឱ្យមានចំនួនសរុប បី (៣) ថ្ងៃ ជួនៗគ្នា ដោយសារជំងឺ នឹងត្រូវការសំបុត្រសុំការលើកលែងតាមការសរសេរជាលាយលក្ខណ៍អក្សរ ដោយអ្នកផ្តល់សេវាថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណ។ *សំបុត្រសុំការលើកលែងតាមការសរសេរជាលាយលក្ខណ៍អក្សរពីអ្នកផ្តល់សេវាថែទាំសុខភាពក៏អាចផ្តល់ឱ្យជំនួសសំបុត្ររបស់មាតាបិតាសម្រាប់អវត្តមានអ្វីមួយក៏បាន។*
- សម្រាប់អវត្តមានទាំងអស់ និងអវត្តមានដែលមិនមានចំនួនសរុប បី (៣) ថ្ងៃ ជួនៗគ្នា មាតាបិតាអាចផ្តល់សំបុត្រសុំការលើកលែងតាមការសរសេរជាលាយលក្ខណ៍អក្សរដោយរៀបរាប់ពីមូលហេតុនៃអវត្តមាននោះ។
- នៅពេលដែលសិស្សបានអវត្តមានដោយសារជំងឺ ត្រូវបានលើកលែងឱ្យដោយសំបុត្រពីមាតាបិតា ដែលមានចំនួនសរុប ប្រាំបី (៨) ថ្ងៃ (តៗគ្នា) អវត្តមានបន្តបន្ទាប់ទាំងអស់ត្រូវតម្រូវឱ្យមានសំបុត្រសុំការលើកលែងតាមការសរសេរជាលាយលក្ខណ៍អក្សរពីអ្នកផ្តល់សេវាថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណ។

**ការផ្តល់ជូនសំបុត្រមិនធានាថាមានការលើកលែងចំពោះអវត្តមានដោយស្វ័យប្រវត្តិនោះទេ ហើយនៅក្រោមការត្រួតពិនិត្យរបស់សាលាដើម្បីសម្រេចពីសុពលភាពនៃសំបុត្រដែលបានផ្តល់ជូន។*

*rev.7/17/23-kr*